ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី
ក្រសួងបរិស្ថាន
លេខៈ ២០០១ ប្រក.បស្ក

រាជធានីភ្នំពេញ. ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៤

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារសិលា នៃក្រសួងបរិស្ថាន
# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.ករម.០១៩៦.២១ ចុះថ្ងៃទី២៤ ខែកមរា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧០៤.១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខ ៣៦០២/០៣ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ០៩១ គ.ជ.ន.ស ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៤ របស់ គណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសិលា
- បានឃើញលិខិតលេខ ០៩៨ សណ.បស្ក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ក្រសួងបរិស្ថាន
- តាមតំរូវការចាំបាច់របស់ក្រសួងបរិស្ថាន

# សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារសិលា នៃក្រសួងបរិស្ថាន ដើម្បីទំនាក់ទំនងការងារជាមួយគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងទំនាក់ទំនងការងារសិលាតាមខ្សែបណ្តោយនៅបណ្តាខេត្ត-ក្រុង ។

**ប្រការ ២ :** ក្រុមការងារសិលាក្រសួងបរិស្ថាន មានសមាសភាពដូចខាងក្រោម :

១. លោក យិន សំរាយ អនុប្រធាននាយកដ្ឋានផែនការ និងកិច្ចការច្បាប់ ប្រធានក្រុម

២.លោក ទាំង មន្នីនាថ អនុប្រធាននាយកដ្ឋានវាយតំលៃធនធានធម្មជាតិ និងគ្រប់គ្រងទិន្នន័យ អនុប្រធានក្រុម

៣. លោក ស្រី ម៉ារ៉ូណារ ប្រធានការិយាល័យសហគមន៍តំបន់ការពារធម្មជាតិ នៃនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ សមាជិក

៤. លោក ឈី ឃួន អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានផែនការ និងកិច្ចការច្បាប់ សមាជិក

៥. លោក ម៉ី សេខឈៀង មន្ត្រីជំនាញ នៃនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ សមាជិក

**ប្រការ ៣** : ភារកិច្ចរបស់ក្រុមការងារសិលាក្រសួងបរិស្ថានមាន :

- កិច្ចសហការការងារជាប្រចាំជាមួយឯកឧត្តមសមាជិកគណៈកម្មាធិការដឹកនាំការងារសិលាក្រសួងបរិស្ថាន និង អគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារសិលា
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមការងារសិលាក្រសួងបរិស្ថាន ដើម្បីដាក់ជូនឯកឧត្តមថ្នាក់ដឹកនាំក្រសួងបរិស្ថានពិនិត្យ និងសំរេច
- គាំទ្របច្ចេកទេសលើការងារបរិស្ថាន ដល់មន្ទីរបរិស្ថានខេត្ត-ក្រុង ការិយាល័យបរិស្ថានស្រុក-ខណ្ឌ និងក្រុមប្រឹក្សាឃុំ-សង្កាត់
- តាមដានវាយតំលៃ និងផ្តល់អនុសាសន៍ជូនថ្នាក់ដឹកនាំក្រសួងបរិស្ថាន
- រាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំក្រសួង អំពីសកម្មភាពការងាររបស់ក្រុមការងារសិលាក្រសួងបរិស្ថាន
- អនុវត្តភារកិច្ចផ្សេងៗដើម្បីប្រយោជន៍ការងារក្រសួងបរិស្ថាន ដែលពាក់ព័ន្ធទៅនឹងកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ។

**ប្រការ ៤** : ខុទ្ទកាល័យទេសរដ្ឋមន្ត្រី អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន អង្គភាពពាក់ព័ន្ធ ដូចក្នុងប្រការ២ ត្រូវអនុវត្តប្រកាសនេះប្រកបដោយប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។៕

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

មក់ ម៉ារ៉េត

បណ្ឌិត.វិទ្យា

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនែកម្មវិធីសិលា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ឯកសារ-កាលប្បវត្តិ